ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ. [illegible]

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជីកប្រឡាយតាមព្រំផ្ទៃដីព្រៃឈើ ដើម្បីការពារ និងរក្សាព្រៃឈើក្នុងឧទ្យានអង្គរ

ជាយូរលង់មកហើយ ព្រៃឈើដែលស្ថិតនៅក្នុងឧទ្យានអង្គរ និងនៅជុំវិញអង្គរជាប្រភេទព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះ មានសត្វស្ទើរគ្រប់ប្រភេទរស់នៅជាព្រៃធម្មជាតិមានសម្រស់ស្រស់បំព្រងគួរជាទីគាប់ចិត្តហើយមិនត្រឹមប៉ុណ្ណោះព្រៃឈើនៅក្នុងឧទ្យានអង្គរ មានផលប្រយោជន៍យ៉ាងសំខាន់ដល់ភាពគង់វង្សនៃប្រាសាទ។ ទោះបីកន្លងមក អាជ្ញាធរជាតិអប្សរា ខិតខំទប់ស្កាត់ និងការពារព្រៃឈើឱ្យប្រសើរឡើងក៏នៅមានជនខិលខូចមួយក្តាប់តូច នៅបន្តកាប់ទន្ទ្រានដីព្រៃឈើបន្តិចម្តងៗ ដើម្បីពង្រីកផ្ទៃដី ផ្ទះសម្បែង ស្រែ ចំការ និងចាប់យកដីព្រៃជាកម្មសិទ្ធិផ្ទាល់ខ្លួន។ល។ ដើម្បីអាចឱ្យអាជ្ញាធរជាតិអប្សរាមានលទ្ធភាពគ្រប់គ្រងទិន្នន័យព្រៃឈើកាន់តែច្បាស់លាស់ និងប្រកបដោយនិរន្តរភាព ដើម្បីការពារ និងរក្សាព្រៃឈើនៅក្នុងឧទ្យានអង្គរឱ្យមានភាពគង់វង្សយូរអង្វែង អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅព្រមទាំងគ្រប់មន្ទីរអង្គភាព និងគ្រប់ស្ថាប័នដែលពាក់ព័ន្ធមេត្តាជ្រាបថា៖ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា នឹងធ្វើការជីកប្រឡាយតាមព្រំផ្ទៃដីព្រៃឈើ ដោយយកប្រឡាយធ្វើបេងការពារការកាប់ទន្ទ្រានព្រៃឈើបន្តទៀត។ ក្រោយពីកំណត់បានព្រំដីព្រៃឈើហើយ អាជ្ញាធរជាតិអប្សរា នឹងដាំដើមឈើឡើងវិញតាមមាត់ប្រឡាយ និងផ្ទៃដីទំនេរដើម្បីបង្កើនគម្របព្រៃឈើ។ ជាក់ស្តែងក្នុងឆ្នាំ២០១៩នេះ អាជ្ញាធរជាតិអប្សរា បានដាំកូនឈើគ្រប់ប្រភេទក្នុងឧទ្យានអង្គរ ចំនួនប្រមាណជាង២ម៉ឺនដើមរួចហើយ។ ការងារជីកប្រឡាយនេះមានចំនួន១៨ខ្សែ មានប្រវែងសរុប២៧,៧៧៧ម៉ែត្រ ដែលស្ថិតនៅតាមទីតាំងដូចខាងក្រោម៖

- ភូមិគោកបេង ភូមិគោកតាចាន់ ភូមិទក្សិណត្បូង និងភូមិគោកដូង សង្កាត់គោកចក ក្រុងសៀមរាប
- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប
- ភូមិក្រវ៉ាន់ ភូមិអារក្សស្វាយ ភូមិអញ្ចាញ ភូមិស្រះស្រង់ត្បូង និងភូមិស្រះស្រង់ជើង សង្កាត់នគរធំ ក្រុងសៀមរាប
- ភូមិអូរទទឹង និងភូមិថ្នល់ទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

ការងារនេះនឹងចាប់ផ្តើមអនុវត្តពីថ្ងៃទី**០១ ខែកញ្ញា ឆ្នាំ២០១៩** តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទូទៅទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ១ កើត ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

សៀមរាប ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៩

**អគ្គនាយក**

**ជុំ សុគន្ធមករា**

**ចម្លងជូន៖**
- សាលាខេត្តសៀមរាប
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- មន្ទីរបរិស្ថានខេត្តសៀមរាប
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរប្រចាំខេត្តសៀមរាប
- ស្នាក់ការតំបន់ការពារទេសភាពអង្គរ
- សាលាក្រុងសៀមរាប
- សាលាស្រុកបន្ទាយស្រី

**"ដើម្បីជូនជ្រាប និងសហការ"**
- គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា

**"ដើម្បីមុខការ និងសហការ"**
- ឯកសារ-កាលប្បវត្តិ